**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីប្រកាសព័ត៌មាន

ចាប់ពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥ មកនេះ មានជនទុច្ចរិតមួយក្រុមបានដើរបំផុសនូវពាក្យចចាមអារ៉ាមតាមតំបន់រោងចក្រវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងថា នៅក្នុងខែធ្នូ ឆ្នាំ២០១៥នេះ គ្រប់រោងចក្រវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជានឹងបិទទ្វារផ្អាកដំណើរការរយៈពេល១ខែ ដែលព័ត៌មាននេះបានបង្កជាក្តីព្រួយបារម្ភដល់បងប្អូនកម្មករនិយោជិត និងនិយោជកក្នុងវិស័យនេះ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈសូមធ្វើការបដិសេធនូវព័ត៌មាននេះ និងសូមបញ្ជាក់ជូនសាធារណៈជន កម្មករនិយោជិត និយោជក និងអង្គការវិជ្ជាជីវៈទាំងអស់ជ្រាបថា ក្រៅពីថ្ងៃឈប់សម្រាកផ្លូវការដែលមាននៅក្នុងប្រកាសលេខ២៤៨កប/ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០១៥ នោះ នៅក្នុងខែធ្នូ ឆ្នាំ២០១៥ នេះ គឺពុំមានការឈប់សម្រាកអ្វីផ្សេងទៀតឡើយ។

ក្រសួងសូមអំពាវនាវដល់សាធារណជន កម្មករនិយោជិត និយោជក និងអង្គការវិជ្ជាជីវៈទាំងអស់សូមមេត្តារក្សាភាពស្ងប់ស្ងាត់ និងបន្តនិរន្តរភាពការងាររបស់ខ្លួនជាធម្មតា ចៀសវាងការចាញ់បោកការឃោសនាអកុសលពីក្រុមជនទុច្ចរិតណាមួយ។

ក្រសួងក៏សូមធ្វើការអំពាវនាវដល់សាធារណជន កម្មករនិយោជិត និយោជក និងអង្គការវិជ្ជាជីវៈនានាមេត្តាសហការផ្តល់ព័ត៌មានជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ចនូវព័ត៌មាននានា ដែលអាចឈានទៅដល់ការរកមុខ និងចាប់ខ្លួនមេខ្លោងបំផុសពាក្យឃោសនាអកុសលនេះ ដើម្បីយកទៅចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត និយោជក និងអង្គការវិជ្ជាជីវៈនានាមេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តទប់ស្កាត់ការឃោសនាអកុសលនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ:(០២៣)៨៨ ២៧ ៦៩*